# វប្បធម៌ចម្ប៉ា

ប្រវត្តិសាស្ត្រនៃរដ្ឋចម្ប៉ា គឺប្រហែលជាកើតឡើងនៅសតវត្សរ៍ទី៣នៃគ.ស. នៅពេលដែលលេចឡើងនូវឈ្មោះ លីន យី (Linyi) ក្នុងឯកសារចិនដែលមានន័យថា ទីក្រុងនៃលីន *"city of the Lin"* ដោយសំដៅលើតំបន់នយោបាយឯករាជ្យមួយស្ថិតនៅតាមសមុទ្រចិនខាងត្បូង។បច្ចុប្បន្នស្ថិតនៅតំបន់ភាគកណ្តាលនៃប្រទេសវៀតណាម។ ចំពោះពាក្យ **លីន យី** ឃើញមានការកត់ត្រាក្នុងឯកសារចិន នៅស.វ.ទី៣ និងនៅអំឡុងឆ្នាំ ៦៥៨គ.ស. លេចឡើងនូវឈ្មោះ ចម្ប៉ា *Campā* ឬ ចាម *Cham* នៅក្នុងសិលាចារឹក C.96 ក្នុងតំបន់ក្រុមប្រាសាទ *Mỹ Sơn*។[១] បន្ទាប់មកទៀត នៅឆ្នាំ៦៦៧ ក្នុងសិលាចារឹកខ្មែរនៅក្តីអង្គ ក្នុងខេត្តព្រៃវែង ក៏ឃើញមានការលើកឡើងពីឈ្មោះ ចាម ដែរ។[២]

គួរបញ្ជាក់ដែរថា រដ្ឋដំបូងៗក្នុងតំបន់អាស៊ីអាគ្នេយ៍ គឺសុទ្ធតែទទួលឥទ្ធិពលពីឥណ្ឌា ( *Indianization*) ទាំងផ្នែកសាសនា (ហិណ្ឌូ) នយោបាយ អក្សរ(សំស្ក្រឹត) និងសិល្បៈផ្សេងៗ ព្រមទាំងមានទំនាក់ទំនងជាមួយនឹងចិន (*Sinicization*) ផ្នែកពាណិជ្ជកម្មផ្លូវសមុទ្រជាដើម ក្នុងនោះរួមមាន ហ្វូណន ទ្វារវត្តី ដ្វា និង ចម្ប៉ានេះជាដើម។ នៅឆ្នាំ ៧៤៩ ស្តេច រុទ្រវរ្ម័ន បានបញ្ជូនសួយសាអាករទៅស្តេចចិន ប៉ុន្តែពុំឃើញមានកត់ត្រានូវឈ្មោះ **លីន យី** ទៀតនោះទេ ដែលជំនួសមកវិញនៅស្តេចនៃចាម។[៣] ក្រោយពីឆ្នាំ៨៥៩គ.ស. នៅក្នុងឯកសារចិនបានកត់ត្រា ពាក្យ *Zhan Cheng* ដែលមានន័យថាទីក្រុងនៃចាម ដែលជាភាសាសំស្ក្រឹត *Campānagara* ឬ *Campāpura* ដែលឃើញមាននៅក្នុងសិលាចារឹក។

សិលាចារឹកដំបូងដែលចារជាភាសាសំស្ក្រឹក បានលេចឡើងនៅក្នុងរាជ្យព្រះបាទភទ្រវរ្ម័ន ដែលបង្ហាញពីកស្តុតាងនៃការជ្រួតជ្រាបនៃសាសនាហិណ្ឌូ ក្នុងសង្គមចម្ប៉ា។ ការបង្ហាញ

---

[១] សូមអាន https://www.researchgate.net/publication/331160829_The_Birth_of_Champa

[២] Schweyer 2012, p. 102.

[៣] *Ibid*, p. 115.

អត្ថបទដោយ៖ អេង តុលា

នោះ គឺតាមរយៈការសសើរទេពសំខាន់ៗក្នុងសាសនាហិណ្ឌូ រួមមាន ព្រះព្រហ្ម ព្រះវិស្ណុ និងព្រះឥសូរ ក្នុងទម្រង់ជាលិង្គ។[៨] ប្រហែលនៅឆ្នាំ៨៧៥ មានរាជ្យវង្សថ្មីមួយដែលមានឈ្មោះថា ឥន្រ្ទបុរ (Indrapura) និងមានទីក្រុងស្ថិតនៅតំបន់កណ្តាលនៃអាណាម (Center Annam) ក្បែរនឹង Dong Duong។ នៅទីនោះ អ្នកស្រាវជ្រាវបានរកឃើញព្រះពុទ្ធរូបអំពីសំរិទ្ធ ដែលមានទម្រង់ដូចនឹងព្រះពុទ្ធនៅស្រីលង្កា ក្នុងស.វ.ទី២ ឬ ទី៣នៃគ.ស.។ តាមរយៈលោក Pierre Dupont បានលើកឡើងថារាជ្យវង្សឥន្រ្ទបុរគឺគោរពព្រះពុទ្ធសាសនាថេរវាទ ដូចទៅនឹងស្រីលង្កា។[៩]

ទីក្រុងសំខាន់ៗនៃរដ្ឋចម្ប៉ារួមមាន *Amaravati* (Quang Nam), *Vijaya* (Binh Dinh), *Kauthara* (Nha Trang), *Panduranga* (Phan Rang) ដែលសុទ្ធសឹងជាទីក្រុងនៃបណ្តុំសំណង់ប្រាសាទហិណ្ឌូ។ ក្រុមប្រាសាទ My son ដែលស្ថិតនៅក្នុងទីក្រុង *Amaravati* បច្ចុប្បន្នស្ថិតក្នុងខេត្ត Quang Nam គឺជាបណ្តុំប្រាសាទដ៏សំខាន់មួយនៅក្នុងសិល្បៈចម្ប៉ា។

យើងក៏ឃើញមានទំនាក់ទំនងរវាងខ្មែរ និងចម្ប៉ាដែរ ដោយចាប់ពីចុងស.វ.ទី១០ និងចាប់ពីក្នុងរាជ្យរបស់ព្រះបាទឧទិយទិត្យវរ្ម័នទី២ ក្នុងស.វ.ទី១១ រហូតដល់ក្នុងរាជ្យរបស់ព្រះបាទជ័យវរ្ម័នទី៧ ក្នុងស.វ.ទី១២។ ទំនាក់ទំនងនេះតាមរយៈការធ្វើសង្រ្គាមរវាងខ្មែរ និងចាម ដែលឃើញមានចម្លាក់នៅតាមប្រាសាទបាយ័ន្ត និងសិលាចារឹក។

សរុបមកនៅចុងស.វ.ទី១៥ ចម្ប៉ា ឬចាមចាប់ផ្តើមបាត់បង់ទឹកដីស្ទើរតែទាំងស្រុង ដោយសារការឈ្លានពានពីដៃវៀត (Đại Việt) និង នៅសល់ត្រឹមតែទីក្រុង *Panduranga* ដែលជាទីក្រុងចុងក្រោយរបស់ចាម រហូតដល់ស.វ.ទី១៧ ចាមត្រូវបានបាត់បង់ទឹកដីទាំងស្រុង។

---

[៨] សូមអាន https://www.persee.fr/docAsPDF/befeo_0336-1519_1951_num_44_1_5049.pdf

[៩] *Ibid*

អត្ថបទដោយ៖ អេង តុលា




រូបលេខ១ ៖ ផែនទីនៃរដ្ឋចម្ប៉ា និងទីក្រុងសំខាន់ៗ

ប្រភព៖ Schweyer




*រូបលេខ២ ៖ ផែនទីនៃរដ្ឋចម្ប៉ា និងទីក្រុងសំខាន់ៗ*

*ប្រភព៖* Schweyer

អត្ថបទដោយ៖ អេង តុលា



រូបលេខ៣ ៖ ចម្លាក់ក្នុងសិល្បៈចាម

ប្រភព៖ Schweyer



រូបលេខ២៤ ៖ ផ្តែរព្រះវិស្ណុបផ្ទុំ

ប្រភព៖ Schweyer

អត្ថបទដោយ៖ អេង តុលា



រូបលេខ២៥ ៖ ចម្លាក់លិង្គមុខ (lingamukha)ក្នុងសិល្បៈចាម

ប្រភព៖ Musée Guimet



រូបលេខ២៦ ៖ ស្រោមលោហៈសម្រាប់ស្រោបលិង្គដែលមានសិលាចារឹក

ប្រភព៖ Schweyer



រូបលេខ៧ ៖ប្រាសាទ Po Nagar de Nha Trang

ប្រភព៖ Schweyer



រូបលេខ៨ ៖ ក្បាច់ចម្លាក់ជើងទម្រដែលមកពីតំបន់ប្រាសាទ My Son

ប្រភព៖ Schweyer

អត្ថបទដោយ៖ អេង តុលា

ឯកសារយោង

http://www.gis-reseau-asie.org/en/chams-vietnam-great-unknown-civilization

https://www.researchgate.net/publication/331160829_The_Birth_of_Champa

https://www.persee.fr/docAsPDF/befeo_0336-1519_1951_num_44_1_5049.pdf

https://www.persee.fr/doc/piot_1148-6023_2009_num_88_1_1724?q=My+son+Champa

https://www.persee.fr/doc/camar_0776-1317_2006_num_34_1_1180?q=Le+style+de+Dong+Duong

AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION